ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ
លេខ: ០៣៧៤/១៩ ក.អ.ជ

ថ្ងៃសុក្រ ១០កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៩

# របាយការណ៍
## វឌ្ឍនភាពការងារប្រចាំខែកុម្ភៈ ឆ្នាំ ២០១៩ របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## I. សេចក្តីផ្តើម

ខែកុម្ភៈ ដើមឆ្នាំ ២០១៩ នេះ ក្រសួងអភិវឌ្ឍន៍ជនបទបានបញ្ចប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ឆ្នាំ ២០១៩-២០២៣ រួចហើយ និងកំពុងចាប់ផ្តើមរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការវិនិយោគសាធារណៈបីឆ្នាំរំកិល ២០២០-២០២២ បន្តទៀត ។ ដោយឡែក ការអនុវត្តន៍ផែនការសកម្មភាពឆ្នាំ ២០១៩ កំពុងដំណើរការដោយរលូន ពិសេសមន្ត្រីជំនាញគ្រប់លំដាប់ថ្នាក់ គ្រប់ខេត្ត កំពុងមមាញឹកចុះពិនិត្យ និងដោះស្រាយបញ្ហាគ្រោះរាំងស្ងួតនៅតាមតំបន់នានាក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការស្តារស្រះទឹក ត្រពាំងទឹក ជួសជុលអណ្តូងស្នប់ និងណែនាំប្រជាពលរដ្ឋឲ្យរក្សាទឹកទុកដើម្បីត្រៀមក្នុងរយៈពេលរាំងស្ងួតខាងមុខនេះ ។

ការងារស្តាបនា ជួសជុលលើកកម្រិតហេដ្ឋារចនាសម្ព័ន្ធរូបវន្ត គមនាគមន៍ជនបទកំពុងបន្តសកម្មភាពតាមផែនការដែលបានគ្រោងទុក ។ កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា រួមទាំងអង្គការមិនមែនរដ្ឋាភិបាលផង នៅបន្តសកម្មភាពដដែល ។ សមិទ្ធផលសម្រេចបានក្នុងខែកុម្ភៈ ឆ្នាំ ២០១៩ មានដូចខាងក្រោមៈ

## II. អំពីការងារគ្រប់គ្រងរបស់ក្រសួង

### ១. ការងាររដ្ឋបាល និងបុគ្គលិក

ដោយគិតត្រឹមដំណាច់ខែកុម្ភៈ ឆ្នាំ ២០១៩ មន្ត្រីរាជការក្របខណ្ឌសរុបមានចំនួន ១ ៨១៤ នាក់ ប្រៀបធៀបនឹងចំនួនមន្ត្រីរាជការកាលពីដំណាច់ខែមករា ឆ្នាំ ២០១៩ មានការថយចុះចំនួន ០២ នាក់។ ក្រសួងបានទទួលលិខិតចូលចំនួន ២០៣ ច្បាប់ លិខិតចេញក្រៅក្រសួងចំនួន ១៤៦ ច្បាប់ ចុះលេខប្រកាស និងសេចក្តីសម្រេចនានា ចំនួន ៦២ ច្បាប់ និងចុះលេខលិខិតបេសកកម្មចំនួន ២៧៧ ច្បាប់ ។

### ២. ក្រុមការងារចុះមូលដ្ឋានតាមដានការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣

ក្នុងខែកុម្ភៈ ឆ្នាំ២០១៩ លេខាធិការដ្ឋានទទួលបានសំណើ សំណូមពររបស់ប្រជាពលរដ្ឋនៅមូលដ្ឋានតាមរយៈវេទិកាសាធារណៈថ្នាក់ជាតិសរុប ចំនួន ២១ ករណី ដែលក្នុងនោះបានដោះស្រាយជូនប្រជាពលរដ្ឋបានចំនួន ០១ ករណី ។

### ៣. ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

ក្នុងខែកុម្ភៈ ឆ្នាំ ២០១៩ ក្រសួងបានអនុវត្តចំណាយ ធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០១៩

អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 639
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល dap.mrd@gmail.com

សម្រេចៈ

- ចំណាយចរន្តអនុវត្តបានចំនួន ១៦៩៧ ៥៤៧ ៣១០ រៀល ស្មើនឹង ១,៣០% នៃច្បាប់ថវិកា
- ចំណាយមូលធនអនុវត្តបានចំនួន ០០ រៀល ។

**៤. ការងារផែនការ និងសហប្រតិបត្តិការអន្តរជាតិ**

- កំពុងប្រមូលធាតុចូលស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២០-២០២២
- បន្តកែសម្រួលផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ ឆ្នាំ ២០១៩-២០២៣
- កំពុងដំណើរការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២០-២០២២ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- ជួបពិភាក្សាជាមួយអង្គការ Engineering Without Borders ស្តីពីការរៀបចំលិខិតគាំទ្រសុំចុះកិច្ចព្រមព្រៀងជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ជួបពិភាក្សាជាមួយអង្គការ World Vision លើការងារសហការជាមួយក្រសួង និងរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ
- ចូលរួមកិច្ចប្រជុំពិភាក្សាលទ្ធផលនៃការរៀបចំផែនការសកម្មភាពដំណាក់កាលទី ៣ (MAP3) ឆ្នាំ ២០១៩ របស់ក្រុមការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅទីស្ដីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចុះណែនាំពីការធ្វើអង្កេតទិន្នន័យអភិវឌ្ឍន៍ជនបទ និងពង្រឹងស្ថិតិ នៅខេត្តមណ្ឌលគិរី និងខេត្តពោធិ៍សាត់
- ចុះណែនាំលើការរៀបចំឯកសារផែនការយុទ្ធសាស្ត្រឆ្នាំ ២០២០-២០២២ លើវិស័យអភិវឌ្ឍន៍ជនបទ នៅខេត្តស្ទឹងត្រែង និងខេត្តបន្ទាយមានជ័យ
- ចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា ស្តីពីផែនការពង្រឹង និងអភិវឌ្ឍអេកូនវានុវត្តន៍ និងសហគ្រិនភាព នៅទីស្តីការក្រសួងផែនការ និងមជ្ឈមណ្ឌលសហប្រតិបត្តិការ កម្ពុជា-កូរ៉េ (CKCC)
- ចូលរួមសិក្ខាសាលា ស្តីពីយុទ្ធសាស្ត្រ និងការរៀបចំសំណាកគំរូសម្រាប់អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ ២០១៩
- ចុះតាមដានការអនុវត្តថវិកាកម្មវិធីនៅខេត្តចំនួន ០២ គឺខេត្តកែប និងខេត្តកំពត
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យផ្លូវជនបទ ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ និងគេហទំព័រក្រសួងអភិវឌ្ឍន៍ជនបទ
- បានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គការចំនួន ០៣ គឺ អង្គការ Saemaul Globalization Foundation អង្គការការីតាសអូស្ត្រាលី (ACR/Caritas Australia) និងអង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព (DPA)
- បានផ្តល់លិខិតអន្តរាគមន៍ដើម្បីនាំចូលរថយន្តចំនួន ០២ គ្រឿង ដោយការបង់ពន្ធជាបន្ទុករបស់រដ្ឋ ជូនអង្គការ iDE
- បានផ្តល់លិខិតអន្តរាគមន៍ដើម្បីសុំចុះបញ្ជីស្លាកលេខ ONG សម្រាប់ទោចក្រយានយន្តថ្មីចំនួន ០១ គ្រឿង របស់អង្គការអ្នកជិតខាងកម្ពុជា (Good Neighbors Cambodia) ។

**៥. ការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

- ចូលរួមកិច្ចប្រជុំប្រកាសស្តីពីការដាក់ឲ្យដំណើរការប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាហិរញ្ញវត្ថុ (FMIS) សាកល្បងសម្រាប់១០ ក្រសួង និងមន្ទីរហិរញ្ញវត្ថុទាំង ២៥ រាជធានីខេត្ត
- បញ្ចប់ការកែសម្រួលផែនការសកម្មភាពដំណាក់កាលទី៣ (MAP3) ឆ្នាំ ២០១៩ ។

**៦. ការងារអធិការកិច្ច និងសវនកម្ម**

- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃការអនុវត្តផែនការឆ្នាំ២០១៨
- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីមូលដ្ឋានគ្រឹះគណនេយ្យ និងការចុះបញ្ជី សម្រាប់ការអនុវត្តគម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។

## III. សកម្មភាពការងារបច្ចេកទេស

**១. ការងារអភិវឌ្ឍន៍ផ្លូវជនបទ**

- គម្រោងសាងសង់ ជួសជុលផ្លូវ និងសំណង់សិល្បការ្យ ឆ្នាំ២០១៨ ជំពូក២១ មាន១០៥ គម្រោងកំពុងបន្តដំណើរការការដ្ឋានបានចំនួន ១០៣គម្រោង លទ្ធផលគិតជាមធ្យមស្មើនឹង ៨៤ % ក្នុងនោះមាន ៖
    - ផ្លូវកៅស៊ូប្រវែង ៨២,៣៥ គ.ម
    - ផ្លូវបេតុងប្រវែង ៦,៧៤៤ គ.ម
    - ផ្លូវក្រាលក្រួសក្រហមប្រវែង ៣៨៧,៨៦ គ.ម
    - សំណង់លូមូល លូជ្រុង ៥៦៤ កន្លែង
    - ស្ពានបេតុងចំនួន ២៦ កន្លែង ប្រវែង ១៣១១ម
- ការងារថែទាំខួប ប្រចាំ និងជួសជុលបន្ទាន់ឆ្នាំ ២០១៩ កំពុងដំណើរការនីតិវិធី ។

**២. ការងារផ្គត់ផ្គង់ទឹកជនបទ**

- ជួសជុលអណ្តូងស្នប់ ចំនួន ០១ នៅខេត្តព្រះវិហារ
- បានខួងអណ្តូងជូនកងពលតូចទ័ពធំត្រយោង និងគ្រួសារទ័ពចំនួន ០២ អណ្តូង នៅខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយគម្រោងឧបត្ថម្ភធនដល់គ្រួសារក្រីក្រ គ្មានលទ្ធភាពតបណ្តាញទឹកស្អាត នៅស្រុកពោធិ៍រៀង ខេត្តព្រៃវែង និងស្រុកល្វាឯម ខេត្តកណ្តាល ។

**៣. ការងារថែទាំសុខភាព និងអនាម័យជនបទ**

- បានសាងសង់បង្គន់អនាម័យចាក់ទឹកតាមផ្ទះឯកជន ចំនួន ១៨ ខ្នងផ្ទះ នៅខេត្តកំពង់ចាម
- បានចុះត្រួតពិនិត្យតាមដាន និងបំផុសការលើកកម្ពស់អនាម័យនៅសហគមន៍ផ្សារតូច សហគមន៍រថភ្លើងB សហគមន៍ស្ទឹងកំបុត និងសហគមន៍បឹងឈូក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

- បានរៀបចំប្រជុំដើម្បីពិនិត្យស្ថានភាពអនាម័យទឹកស្អាត ក្នុងស្រុកត្រាំកក់ ស្រុកសំរោង និងស្រុកព្រៃកប្បាស ខេត្តតាកែវ ជាលទ្ធផលអង្គការ UNICEF បានសម្រេចអនុវត្តកម្មវិធី CLTS ក្នុងស្រុកទាំង ០៣ នេះ សម្រាប់រយៈពេល ០២ ឆ្នាំ ២០១៩ ដល់ ២០២០ ។

**៤. ការងារអភិវឌ្ឍន៍សហគមន៍**

- រៀបចំផែនការសកម្មភាពបណ្តុះបណ្តាលពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) សម្រាប់ឆ្នាំ ២០១៩
- រៀបចំផែនការចុះពិនិត្យ និងសិក្សាភូមិគោលដៅសម្រាប់គម្រោងអភិវឌ្ឍន៍ភូមិចម្រុះ សម្រាប់ឆ្នាំ ២០១៩
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ បានផ្សព្វផ្សាយជ្រើសរើសសិក្ខាកាមសម្រាប់បើកវគ្គសិក្សាក្នុងវគ្គទី១ ឆមាសទី១ ឆ្នាំ ២០១៩
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ បានចុះផ្សព្វផ្សាយជ្រើសរើសសិក្ខាកាមចូលរៀនទាំងក្នុង និងក្រៅមជ្ឈមណ្ឌល តាមរយៈការចែកសេចក្តីជូនដំណឹងដល់មេភូមិចំនួន ២៨ ភូមិ នៅក្នុងឃុំញ៉ែងញ៉ង ស្រុកទ្រាំង និងឃុំស្រែរនោង ស្រុកត្រាំកក់ ។

**៥. ការងារបណ្តុះបណ្តាល**

- មន្ត្រីចូលរួមសិក្ខាសាលាក្នុងប្រទេស ចំនួន ១២០ នាក់ ក្នុងនោះស្រីចំនួន ១៣ នាក់
- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន ២៧ នាក់ ក្នុងនោះស្រីចំនួន ០៤ នាក់
- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេស ចំនួន ០២ នាក់ ក្នុងនោះស្រីចំនួន ០២ នាក់
- បានផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីវគ្គបណ្តុះបណ្តាល ចំនួន ០៣លើក
- បានរៀបចំឯកសារចាត់បញ្ជូនមន្ត្រីដើម្បីទៅចូលរួមវគ្គបណ្តុះបណ្តាល ចំនួន ០២ លើក
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង បានចុះតាមដានសិក្ខាកាមដែលបានបញ្ចប់វគ្គជួសជុល និងថែទាំម៉ាស៊ីនកសិកម្ម ចំនួន ០៤ នាក់ នៅស្រុកកំចាយមារ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តស្វាយរៀងបានចុះតាមដាន និងវាយតម្លៃសិក្ខាកាមបញ្ចប់វគ្គ ចំនួន ០៩ ភូមិ នៅស្រុករំដួល
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានផ្សព្វផ្សាយជ្រើសរើសសិក្ខាកាមចូលរៀនវគ្គទី ១ ឆមាសទី ១ ឆ្នាំ ២០១៩
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង បានផ្សព្វផ្សាយជ្រើសរើសសិក្ខាកាមចូលរៀនវគ្គថ្មី សម្រាប់ឆ្នាំ២០១៩
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តពោធិ៍សាត់ បានធ្វើការផ្សព្វផ្សាយជ្រើសរើសសិក្ខាកាមចូលរៀនវគ្គថ្មី សម្រាប់ឆមាសទី១ ឆ្នាំ២០១៩
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពត បានផ្សព្វផ្សាយជ្រើសរើសសិក្ខាកាមចូលរៀនតាមវគ្គនីមួយៗ និងបានបើកវគ្គកុំព្យូទ័ររដ្ឋបាល ចំនួន ០២ វគ្គ និងភាសាអង់គ្លេស ០១ វគ្គ មានសិក្ខាកាមសរុប ៤៧ នាក់ ក្នុងនោះមានស្រីចំនួន ៣៤ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ ទើបត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៩ ដូច្នេះមជ្ឈមណ្ឌលកំពុងរៀបចំឯកសារដើម្បីចាប់ផ្តើមវគ្គបណ្តុះបណ្តាល

- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តបន្ទាយមានជ័យ ទើបត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៩ ដូច្នេះមជ្ឈមណ្ឌលកំពុងរៀបចំឯកសារដើម្បីផ្សព្វផ្សាយវគ្គបណ្តុះបណ្តាល
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តសៀមរាប ទើបត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៩ ដូច្នេះមជ្ឈមណ្ឌលកំពុងរៀបចំឯកសារដើម្បីផ្សព្វផ្សាយវគ្គបណ្តុះបណ្តាល និងស្រង់ទិន្នន័យដែលត្រូវធ្វើការបណ្តុះបណ្តាលនាពេលខាងមុខ ។

**៦. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ**

- គិតត្រឹមថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០១៩ ប្រតិបត្តិករឥណទានជនបទដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តអនុវត្តផ្ទាល់ និងសហការជាមួយដៃគូ និងសកម្មភាពការងារឥណទានដែលអនុវត្តដោយសហគមន៍សន្សំប្រាក់បានផ្តល់ឥណទានសរុប ចំនួន ៤ ៣៨២ ៩១៨ ៧៣៥ រៀល (បួនបីលានបីរយប៉ែតសិបពីរលានប្រាំបួនរយដប់ប្រាំបីពាន់ប្រាំពីររយសាមសិបប្រាំរៀល) ស្មើនឹង ១ ១១៤ ៩៥៥,៦៤ ដុល្លារអាមេរិក (មួយលានមួយរយដប់ពាន់ប្រាំបួនរយហាសិបប្រាំដុល្លារនិងហុកសិបបួនសេន) (១USD=៤០០០រៀល) មានអ្នកខ្ចីសរុបចំនួន ៤ ៥៤៣ នាក់នៅភូមិគោលដៅចំនួន ១៩៦ភូមិ ៧១ឃុំ ៣២ស្រុក ក្នុងខេត្តគោលដៅចំនួន ១៥
- បានធ្វើការបូកសរុប និងសម្របសម្រួលគាំទ្រផ្នែកបច្ចេកទេសគ្រប់គ្រងធនាគារស្រូវដល់សហគមន៍ដែលមានស្រូវសរុបចំនួន ១០ ០០០ គ.ក្រ ស្ថិតនៅដៃសមាជិកកំពុងប្រើប្រាស់សរុបចំនួន ៨៦ នាក់ ស្រី ៦៤ នាក់ ។

**៧. ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច**

- បានចូលរួម វាយតម្លៃអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចកួយ ចំនួន ០៣ សហគមន៍ នៅឃុំសាលាវិស័យ ស្រុកប្រាសាទបាល្ល័ង្គ ខេត្តកំពង់ធំ
- បានចូលរួមធ្វើបទបង្ហាញអំពីគោលនយោបាយអភិវឌ្ឍន៍ជនជាតិដើមភាគតិច សារាចរណ៍ណែនាំ ស្តីពីស្វ័យអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច និងដំណើរការរៀបចំបទបញ្ញាផ្ទៃក្នុងនៃការប្រើប្រាស់ និងគ្រប់គ្រងដីសហគមន៍ជនជាតិដើមភាគតិច ដល់អាជ្ញាធរថ្នាក់ក្រោមជាតិ និងសហគមន៍ នៅសាលាស្រុករៀង ខេត្តព្រះវិហារ ។

**៨. ការងារយេនឌ័រ**

- បានចូលក្រាបថ្វាយបង្គំគាល់ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង និងសម្តេចមហាក្សត្រព្រះវររាជមាតាជាតិខ្មែរ ក្នុងឱកាសអបអរសាទរខួបលើកទី១០៨ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ ២០១៩
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីយេនឌ័រ និងកាបន្សាំនឹងការបម្រែបម្រួលអាកាសធាតុ ។

**៩. ការងារប្រយុទ្ធនឹងជំងឺអេដស៍**

- បានរៀបចំប្រជុំក្រុមការងារដើម្បីរៀបចំផែនការសម្រាប់អនុវត្តការងារ ឆ្នាំ២០១៩ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។

១០. ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ

- បានចូលរួមសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងផែនការថវិកា ឆ្នាំ២០១៩ របស់ គ.ជ.អ.ប ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ប្រជុំត្រួតពិនិត្យ និងស្តាប់របាយការណ៍វឌ្ឍនភាពឆ្នាំ២០១៨ របស់ គ.ជ.អ.ប លើកកម្មវិធីអនាម័យលើស្រុកទាំង១៥ ។

## IV. **ការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការផ្សេងៗ**

### ១. គម្រោងកែលម្អផ្លូវជនបទ ដំហាន ២

អនុវត្តក្នុងខេត្តគោលដៅចំនួន១០ គឺ ខេត្តត្បូងឃ្មុំ កំពង់ចាម តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ គិតត្រឹមដំណាច់ខែកុម្ភៈនេះ គម្រោងសម្រេចបាន ៖

- ខេត្តត្បូងឃ្មុំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១៩៣,៩ គ.ម សម្រេចបាន៩៤,៨៨%
- ខេត្តតាកែវ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១០៤,០៨គ.ម សម្រេចបាន ៣៩,៦៦%
- ខេត្តកំពង់ស្ពឺ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ខ្សែ មានប្រវែងសរុប ១៦១,៦០គ.ម សម្រេចបាន ៤៥,៥៤%
- ខេត្តកំពង់ឆ្នាំង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១២៦,៣០គ.ម សម្រេចបាន ៤០,២៨%
- ខេត្តកំពង់ធំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៤ខ្សែប្រវែង ១១៣,៤០គ.ម សម្រេចបាន ៣៣,៨៥%
- ខេត្តសៀមរាប : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៦ខ្សែ មានប្រវែងសរុប ១២៦,២០ គ.ម សម្រេចបាន ១៨,៩៦%
- ខេត្តពោធិ៍សាត់ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ខ្សែ មានប្រវែងសរុប ១២៥,៥០គ.ម សម្រេចបាន ៨៣,៩២%
- ខេត្តបាត់ដំបង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៨ខ្សែ មានប្រវែងសរុប ១០១,២០គ.ម សម្រេចបាន ៨៦,២៩%
- ខេត្តបន្ទាយមានជ័យ :បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៥ខ្សែ មានប្រវែងសរុប ៩០,៧០ គ.ម សម្រេចបាន ៨២,០៤%
- ខេត្តកំពង់ចាម : បាន និងកំពុងដំណើរការសាងសង់ផ្លូវក្រាលបេតុងចំនួន ០៦ខ្សែ មានប្រវែងសរុប ៥០គ.ម សម្រេចបាន ៩៣,០៧% ។

### ២. គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទជំហានទី ៦

គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទជំហានទី ៦ ជាគម្រោងសហហិរញ្ញប្បទានឥតសំណងរវាងរដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ តាមរយៈធនាគារ KfW និងរាជរដ្ឋាភិបាលកម្ពុជា អនុវត្តនៅខេត្តបន្ទាយមានជ័យ ។ អង្គភាពគ្រប់គ្រងគម្រោងសហការជាមួយក្រុមហ៊ុន GOPA Consultant

បាន និងកំពុងរៀបចំនីតិវិធីដេញថ្លៃ ។

**៣. គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ**

គម្រោងសាច់ប្រាក់ពលកម្ម សម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ មានរយៈពេល ០៣ឆ្នាំ និងផ្តោតលើការស្តារ និងកែលំអផ្លូវជនបទប្រវែងប្រមាណ ៦៨៧គីឡូម៉ែត្រ ដែលអនុវត្តក្នុងខេត្តគោលដៅចំនួន ១២ គឺ ខេត្តកណ្តាល តាកែវ ស្វាយរៀង កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ស្ពឺ ព្រៃវែង និងខេត្តឧត្តរមានជ័យ ។ គម្រោងបាន និងកំពុងអនុវត្តចំនួន ១៥៧ គម្រោង ប្រវែង ១៥៩ ០៣៤ ម៉ែត្រ។

**៤. គម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទទី ២**

- សាងសង់ថ្នាលហាលលាមកមានជំបូលថ្លាបេញ (Model3) នៅស្រុកសង្កែ ខេត្តបាត់ដំបង និងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ សម្រេចបាន ៨៥%
- សាងសង់ថ្នាលហាលលាមកមានភ្ជាប់ឡជីវឧស្ម័ន (Model1) នៅសង្កាត់ចំការសំរោង ក្រុងបាត់ដំបង សម្រេចបាន ៥៥%
- ជួសជុលស្រះសហគមន៍ ចំនួន ០១ កន្លែង នៅខេត្តពោធិ៍សាត់ ។

**៥. គម្រោងផ្គត់ផ្គង់ទឹកជនបទ និងកែលម្អផ្លូវជនបទក្រោមហិរញ្ញប្បទានឥតសំណងរបស់សាធារណៈរដ្ឋ ប្រជាមានិតចិន**

គម្រោងផ្គត់ផ្គង់ទឹកជនបទ និងកែលម្អផ្លូវជនបទដំហាន ១ ក្រោមហិរញ្ញប្បទានឥតសំណងរបស់សាធារណៈរដ្ឋប្រជាមានិតចិន ដោយផ្តោតលើសកម្មភាពធំៗចំនួនពីរ គឺ ការផ្គត់ផ្គង់ទឹកជនបទដែលអនុវត្តក្នុងខេត្តគោលដៅចំនួន ០៦ គឺ ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ធំ កណ្តាល ត្បូងឃ្មុំ និងខេត្តស្វាយរៀង និងការកែលម្អផ្លូវជនបទ ដែលអនុវត្តក្នុងខេត្តគោលដៅចំនួន ០៤ គឺ ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ធំ និងខេត្តកំពង់ចាម ។ គិតត្រឹមខែកុម្ភៈនេះ គម្រោងសម្រេចបាន៖

- បាន និងកំពុងសាងសង់ផ្លូវចំនួន ០៧ ខ្សែ ប្រវែង ៣៥,៥ គ.ម ក្នុងខេត្តគោលដៅទាំង ០៤ សម្រេចបាន ៩៦ %
- បានសាងសង់ស្ពានបេតុង ចំនួន ០១ ប្រវែង ១២៥ ម៉ែត្រ នៅខេត្តកំពង់ស្ពឺ សម្រេច ១០០%។

**៦.គម្រោងអភិវឌ្ឍន៍សហគមន៍ចម្រុះតាមដងទន្លេមេគង្គ**

គម្រោងនេះជាជំនួយហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលចិនក្នុងក្របខណ្ឌមេគង្គឡានឆាងសម្រាប់ឆ្នាំ ២០១៨ អនុវត្តលើការងារសហគមន៍ចម្រុះនៅខេត្តជាប់ដងទន្លេមេគង្គចំនួន ០៤ គឺ ខេត្តកណ្តាល ព្រៃវែង ក្រចេះ និងខេត្តស្ទឹងត្រែង ។ គម្រោងបានបញ្ចប់ក្នុងខែកុម្ភៈនេះ និងបានសម្រេចសមិទ្ធផលមានដូចជា៖

- ចុះពិនិត្យ និងវាយតម្លៃសមិទ្ធផលគម្រោងដើម្បីបិទបញ្ចប់នៅចុងខែកុម្ភៈ ឆ្នាំ ២០១៩
- កំពុងជីកប្រឡាយទឹក ០១ ខ្សែប្រវែង ៣៥០ ម៉ែត្រ សាងសង់ផ្លូវ ០២ ខ្សែស្របប្រឡាយប្រវែង ៧០០ ម៉ែត្រ និងសាងសង់ទ្វារទឹក ០១ កន្លែង ។

## V. សេចក្តីសន្និដ្ឋាន

ក្រោយពីក្រសួងចេញសេចក្តីណែនាំស្តីពីវិធានការកាត់បន្ថយការខ្វះខាតទឹកប្រើប្រាស់ដោយសារគ្រោះរាំងស្ងួតមក មន្ត្រីគ្រប់លំដាប់ថ្នាក់ ពិសេសមន្ត្រីជំនាញពាក់ព័ន្ធកំពុងចុះតាមមូលដ្ឋានជួយណែនាំ និងដោះស្រាយទឹកជូនប្រជាពលរដ្ឋនៅជនបទយ៉ាងសកម្ម ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋជនបទប្រកបដោយការទទួលខុសត្រូវ។ ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ ២០១៩-២០២៣ ក្រសួងបានសម្រេចទិសដៅអាទិភាពចំនួន០៤ សម្រាប់ចូលរួមពង្រឹងសេវាសាធារណៈ នៅមូលដ្ឋានជនបទរួមមាន ការពង្រឹងស្ថាប័ន ការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្ស ការស្ថាបនា ជួសជុល លើកកម្រិតហេដ្ឋារចនាសម្ព័ន្ធរូបវន្ត គមនាគមន៍ និងសេវាសាធារណៈ ការលើកកម្ពស់សុខភាព ការអប់រំ និងលក្ខខណ្ឌនៃការរស់នៅ ការបង្កើតការងារ មុខរបរ សហគ្រិនភាព និងសកម្មភាពសេដ្ឋកិច្ច ដើម្បីចូលរួមអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣ ឲ្យទទួលបានជោគជ័យ ។/.

**រដ្ឋមន្ត្រី**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**